# សិក្ខាសាលាថ្នាក់ខេត្តស្តីអំពី កសិកម្ម និង ការអភិវឌ្ឍន៍ជនបទក្នុងខេត្តព្រៃវែង

នៅថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០០៩ អង្គការ សេដាក សហការជាមួយមន្ទីរកសិកម្មខេត្ត បានរៀបចំសិក្ខាសាលាថ្នាក់ខេត្តមួយ ស្តីអំពីកសិកម្ម និងការអភិវឌ្ឍន៍ជនបទក្នុងខេត្តព្រៃវែង ។ កិច្ចប្រជុំនេះត្រូវបានប្រារព្ធឡើង នៅសាលប្រជុំមន្ទីរកសិកម្មខេត្ត។ ក្នុងនោះមានអ្នកចូលរួមប្រមាណ ៨0 នាក់រួមមានអភិបាលរងខេត្ត ប្រធាន និងបុគ្គលិករបស់មន្ទីរកសិកម្មខេត្ត មន្ទីរកិច្ចការនារី មន្ទីរ អប់រំយុវជន និងកីឡា មន្ទីរសុខាភិបាល មន្ទីរធនធានទឹកនិងឧតុនិយម អភិបាលស្រុក អ្នកតំណាង អង្គការក្រៅរដ្ឋាភិបាលដែលធ្វើការនៅខេត្តព្រៃវែង និងអ្នកតំណាងសហករកសិករ និងក្រុមព្រឹក្សាឃុំ ។ សិក្ខាសាលានេះប្រារព្ធឡើងក្រោមធិបតីយភាព លោកអភិបាលរងខេត្តព្រៃវែង ប្រធានមន្ទីរកសិកម្ម និងប្រធានអង្គការសេដាក។ គោលបំណងនៃសិក្ខាសាលានេះគឺដើម្បី :

- បង្ហាញសម្មិទ្ធិផល និងបទពិសោធន៍ នៃអន្តរាគមន៍របស់អង្គការ សេដាក នៅក្នុងការងារកសិកម្ម និងអភិវឌ្ឍជនបទ ។
- អនុញ្ញាតិអោយកសិករឆ្នើមបានបង្ហាញបទពិសោធន៍ និងការរីកចំរើន របស់ពួកគេក្រោយពីបានសហការជាមួយ អង្គការ សេដាក ។
- ប្រារព្ធខួប ១០ ឆ្នាំរបស់អង្គការ សេដាក ដែលបានធ្វើការនៅក្នុងខេត្តព្រៃវែង

នៅអំឡុងពេលសិក្ខាសាលា កសិករដែលទទួលជោគជ័យបំផុតលើការងារកសិដ្ឋានពហុប្រយោជន៍ ក្រុមសន្សំប្រាក់ អ្នកផ្ទុកមេរោគអេដស៍ និងសហគ្រិនវ័យក្មេង ត្រូវបានអញ្ជើញឱ្យចែករំលែកបទពិសោធន៍របស់ពួកគេ។

គួរកត់សម្គាល់ថា សេដាក បានអនុវត្តការងារកសិកម្ម និងអភិវឌ្ឍន៍ជនបទ នៅក្នុងខេត្តព្រៃវែង ចាប់តាំងពីឆ្នាំ ១៩៩៩ មកដែលបានចាប់ផ្តើមដំបូង នៅក្នុងភូមិចំនួនពីរ ស្ថិតក្នុងឃុំឈើកាច់ ស្រុកបាភ្នំ។ បច្ចុប្បន្ន អង្គការ សេដាក បាននិងកំពុងធ្វើការនៅក្នុងភូមិចំនួន ៥៤៨ ស្ថិតក្នុង ៧៥ ឃុំ និង ១២ ស្រុកនៅទូទាំងខេត្ត។ មានគ្រួសារកសិករចំនួន ១៤.៧១៦ គ្រួសារបានចូលរួម និងទទួលផលប្រយោជន៍ពីកម្មវិធីកសិកម្មនិងអភិវឌ្ឍន៍ជនបទ របស់អង្គការ សេដាក។

